# សេចក្តីថ្លែងការណ៍

## គំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ

## ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៨

**ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៨ នៅសណ្ឋាគារ អ៊ីនធឺកង់ទីណង់តាល់ ភ្នំពេញ កម្ពុជា**

**<u>ដំណោះស្រាយអាជីវកម្មប្រសើរ គឺនឹងបង្ហាញនៅឱកាសពិធីសម្ពោធអាជីវកម្មស្អាតស្អំ</u>**

គំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំបើកសម្ពោធជាសាធារណៈនៅថ្ងៃនេះ ។ គំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ ជាកិច្ចប្រឹងប្រែងមួយឈានមុខដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យឯកជន ធ្វើអោយប្រសើរឡើងនូវបរិយាកាសអាជីវកម្ម តាមរយៈការប្រកួតប្រជែងយុត្តិធម៌ និង លើកកម្ពស់ការអនុវត្តអាជីវកម្មស្អាតស្អំនៅក្នុងប្រតិបត្តិការខាងក្នុងរបស់ក្រុមហ៊ុន។ សារនៅលើឡូហ្គូគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ គឺ «អាជីវកម្មសុចរិត និងការប្រកួតប្រជែងយុត្តិធម៌ » រួមជាមួយនឹងគំនិតផ្តួចផ្តើមផ្សេងៗទៀត ។

ហេតុអ្វីបានជាក្រុមហ៊ុនខ្នាតតូច ខ្នាតធំជាង ៤០ ទាំងក្នុងស្រុក និងបរទេសជួបជុំគ្នាធ្វើពិធីសម្ពោធគំនិតផ្តួចផ្តើមអាជីវកម្មនេះ ? ហេតុអ្វីគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ ជាដំណោះស្រាយអាជីវកម្មប្រសើរបំផុត? អ្នកគាំទ្រគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ មានជំនឿថា ដើម្បីរក្សាស្ថេរភាពរីកចំរើនសេដ្ឋកិច្ច និងរៀបចំការអភិវឌ្ឍនាពេលអនាគតប្រទេសកម្ពុជា ដូចជាផែនការបើកទីផ្សារភាគហ៊ុននៅកម្ពុជាជាសាធារណៈ ដូចនេះក្រុមហ៊ុនជាច្រើនត្រូវតែចូលរួមជម្រុញឲ្យបរិយាកាសអាជីវកម្មបានប្រសើរឡើង និងប្រតិបត្តិការដោយសុចរិត ។ ប្រទេសកម្ពុជាគួរចាត់ទុកថា ជាកន្លែងដ៏ប្រសើរបំផុតសម្រាប់ការធ្វើអាជីវកម្មនៅតំបន់អាស៊ីអាគ្នេយ៍ មិនគួរជាប្រទេសដែលទទួលរងហានិភ័យខ្លាំងបំផុតនោះទេ ។

ប្រទេសកម្ពុជាជាកន្លែងសម្រាប់ធ្វើអាជីកម្មរួចជាស្រេច ខណៈដែលកិច្ចខិតខំប្រឹងប្រែងដើម្បីភាពរីកចំរើននេះជាកិច្ចការលំបាកនឹងសម្រេចបាន ។ បើតាមការស្រាវជ្រាវថ្មីៗនេះ របស់ធនាគារពិភពលោក ដែលគេអាចឃើញមានប្រទេសធ្វើអាជីវកម្មឈានមុខ ក្នុងនោះកម្ពុជាឈានដល់ចំនុច ១៥ ដែលងាយស្រួលធ្វើអាជីវកម្មមួយ។ ទោះយ៉ាងនេះក្តី ប្រទេសកម្ពុជានៅតែស្ថិតក្នុងលំដាប់ថ្នាក់ទី ១៣៥ នៃ១៨១ប្រទេស តាមរបាយការណ៍ឆ្នាំ ២០០៩របស់ធនាគារពិភពលោក ស្តីពីការធ្វើអាជីវកម្ម ។ ការចាត់ថ្នាក់ត្រង់កំរិតទាបមួយសម្រាប់ប្រទេសកម្ពុជាបង្ហាញថាឲ្យឃើញពីផលលំបាកបរិយាកាសធ្វើអាជីវកម្ម ជារឿយៗ ទាក់ទងនឹងពេលវេលាការចំណាយ សេវាក្រៅផ្លូវការសម្រាប់បើកអាជីវកម្ម និងសុំអាជ្ញាបណ្ណអាជីវកម្ម ។

ក្រុមហ៊ុនគាំទ្រគំនិតផ្តួចផ្តើមអាជីវកម្មទាំងអស់មានជំនឿថា ចាំបាច់ណាស់ដែលក្រុមហ៊ុនទាំងនោះត្រូវជម្រុញគាំទ្រដល់រដ្ឋាភិបាលដើម្បីលើកស្ទួយបរិយាកាសអាជីវកម្ម និងការប្រកួតប្រជែងយុត្តិធម៌ ។ ក្រុមហ៊ុនផងដែរត្រូវប្តេជ្ញាប្រតិបត្តិអាជីវកម្មរបស់ខ្លួនឲ្យស្អាតស្អំ ។ វាចាំបាច់ណាស់ក្រុមហ៊ុនទាំងអស់ត្រូវជម្រុញសុចរិតភាពឲ្យបានមិនថាប្រតិបត្តិការក្រៅក្រុមហ៊ុននោះទេ គឺទាំងក្នុងក្រុមហ៊ុនផងដែរ ។ ឧទាហរណ៍ និយោជិតមិនត្រូវរំពឹងចង់បាន ឬសូកប៉ាន់ចំពោះការចុះកិច្ចសន្យាថ្មីណាមួយឡើយ ។ ការបង់ថ្លៃក្រៅផ្លូវការ គឺមិនបានផ្តល់តម្លៃសំរាប់ក្រុមហ៊ុនគាំទ្រគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំនោះទេ ។

## គំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ គឺជាអាជីវកម្មឈានមុខ

ខណៈដែលគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ ជាបញ្ហាថ្មីមួយសម្រាប់សាធារណ ការប្រកាសជាសាធារណៈគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំនេះបានផ្តួចផ្តើមឡើងតាំងពីឆ្នាំមុនមកម្លេះ ។ ក្រោមការសម្របសម្រួលពីអង្គការផេកកម្ពុជា ឧបត្ថមថវិការដោយទីភ្នាក់ងារសហរដ្ឋអាមេរិចសម្រាប់ការអភិវឌ្ឍអន្តរជាតិ គោលដៅ គោលការណ៍ និងផែនការសកម្មភាពគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំឆ្លុះបញ្ចាំងពីកិច្ចការអទិភាពរបស់អ្នកដឹកនាំអាជីវកម្មនៅទូទាំងប្រទេស ។ រាល់គោលការណ៍ និងសកម្មភាពទាំងនោះបានមកពីការពិភាក្សាជាក្រុមនៃម្ចាស់អាជីវកម្មទូទាំងប្រទេស និងបានមកពីការពិភាក្សាជាមួយអ្នកដឹកនាំអាជីវកម្ម មន្ត្រីរដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលធ្វើការលើការអភិវឌ្ឍវិស័យឯកជន ។

លើសពីនេះទៀត គំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ ដឹកនាំដោយគណៈកម្មាការអចិន្ត្រៃយ៍ មួយដែលមានអ្នកដឹកនាំអាជីវកម្មសំខាន់ៗចូលរួមជាតំណាង ៧ក្រុមហ៊ុន គឺ ហាហ្គារ កម្ពុជា (Hagar Cambodia) ធនាគារអេស៊ីលីដា ធនាគារ ANZ Royal ក្រុមហ៊ុនភេសជ្ជៈកម្ពុជា ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេអឹមខេ Marison Kan & Associates និងក្រុមហ៊ុនទេសចរណ៍រើលដ៏ អ៊ិចប្រេស ។ គណៈកម្មាការអចិន្ត្រៃយ៍ និងក្រុមហ៊ុន ៥០យល់ឃើញថា គំនិតផ្តួចផ្តើមអាជីវកម្ម ស្អាតស្អំជា «ដំណោះស្រាយអាជីវកម្មប្រសើរបំផុត » ហើយចុះបញ្ជីគាំទ្រគំនិតផ្តួចផ្តើមនេះ គឺ ទទួលខុសត្រូវកំនត់ទិសដៅគម្រោងកំពុងអនុវត្ត ។

## តើគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំនឹងធ្វើអ្វីខ្លះ ?

សកម្មភាពគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ បង្កើតឡើងដើម្បីសម្រេចគោលដៅរបស់ខ្លួន គឺលើកស្ទួយបរិយាកាសអាជីវកម្មឲ្យប្រសើរឡើង និងប្រតិបត្តិការអាជីវកម្មដោយសុចរិត ។

ការងារសំខាន់បំផុតមួយនៃគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ គឺក្រុមហ៊ុនគាំទ្រទាំងអស់ធ្វើការចងក្រង «បណ្តាញអាជីវកម្មស្អាតស្អំមួយ» ហើយនឹងបន្តអភិវឌ្ឍបណ្តាញនេះសម្រាប់ឆ្នាំក្រោយទៀត ។ បណ្តាញអាជីវកម្មស្អាតស្អំនឹងខិតខំធ្វើកំណែទម្រង់អាជីកម្មបន្ថែមទៀត ចែករំលែកបទពិសោធន៍អំពីរបៀបធ្វើអាជីវកម្មនៅកម្ពុជា និងធ្វើជាបណ្តាញផ្គត់ផ្គង់មួយដ៏ប្រសើរសម្រាប់អាជីវកម្មផ្សេងៗ ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិល ។

គំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ នឹងបំពេញចន្លោះខ្វះខាតនៃព័ត៌មាន ផ្តល់ឲ្យអាជីវកម្មងាយស្រួលដល់ការប្រើប្រាស់ច្បាប់ ប្រកាស និងបទបញ្ញត្តិពាក់ព័ន្ធ និងបង្កើតគោលការណ៍ណែនាំងាយយល់មួយចំនួនដើម្បីបំពេញនូវកង្វះខាតទាំងនោះ ។ គំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំនឹងជួយបង្កើនការពិភាក្សារវាងសាធារណៈ និងផ្នែកឯកជន លើកយកបញ្ហាអាជីវកម្មស្អាតស្អំនៅក្នុងវេទិកាពិភាក្សាលើវិស័យឯកជនរបស់រាជរដ្ឋាភិបាល និងជម្រុញលើកទឹកចិត្តដល់អាជីវកម្មគាំទ្រគំនិតផ្តួចផ្តើមទាំងអស់បានចូលរួមផងដែរ ។

គំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំនឹងផ្តល់ព័ត៌មាន និងឧបករណ៍មួយចំនួនដល់ក្រុមហ៊ុនគាំទ្រទាំងអស់ប្រតិបត្តិអាជីវកម្មឲ្យបានស្អាតស្អំ ។ នឹងមានកញ្ចប់ឯកសាររួមមាន គោលការណ៍ដែលអាចទទួលយកបាន និងងាយយល់មួយចំនួនចាំបាច់សម្រាប់ប្រតិបត្តិអាជីវកម្មឲ្យស្អាតស្អំដូចជា ក្រមសីលធម៌ ឬគោលការណ៍ប្រឆាំងអំពើពុករលួយ ។ កញ្ចប់ឯកសារនេះនឹងចែកជូនក្នុងវគ្គសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ទៅតាមប្រធានបទពាក់ព័ន្ធ និងឆ្លុះបញ្ចាំងបទពិសោធន៍នៃការប្រតិបត្តិល្អៗ ផងដែរជាមួយអ្នកឯកទេសអន្តរជាតិ ។

## រក្សាភាពស្អាតស្អំ

ដោយសារកិត្តិស័ព្ទ និងសេចក្តីថ្លៃថ្នូរនៃគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ ជាកត្តានាំឲ្យជោគជ័យ ដូចនេះ ចាំបាច់ណាស់ត្រូវមានយន្តការមួយចំនួនធានាឲ្យមានស្តង់ដារជាមូលដ្ឋាន ។ គណៈកម្មាការអចិន្ត្រៃយ៍អាជីវកម្មស្អាតស្អំបានសម្រេចរៀបចំវិញ្ញាបនបត្រសម្រាប់អាជីវកម្មគាំទ្រគំនិតផ្តួចផ្តើមនេះយកទៅប្រើប្រាស់នាពេលឆាប់ៗខាងមុខ ។ ដំណើរការផ្តល់វិញ្ញាបនបត្រគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ នឹងបញ្ចប់នាពេលឆាប់ៗ ហើយគ្រោងនឹងចាប់ផ្តើមនៅខែមករាឆ្នាំ២០០៩ខាងមុខនេះ ។ នេះជានិតិវិធីជាក់លាក់មួយ ដើម្បីឲ្យប្រាកដថា អាជីវកម្មមានកម្មសិទ្ធិលើរាល់អាជ្ញាបណ្ណនៃប្រតិបត្តិការអាជីវកម្មដែលចាំបាច់ ហើយអាជីវកម្មនោះមានគោលការណ៍ជាក់លាក់ និងអនុវត្តគោលការណ៍ទាំងនោះ ដូចនឹងគោលការណ៍ប្រឆាំងអំពើពុករលួយ ឬក្រមសីលធម៌ ។

ការរក្សាកិត្តិស័ព្ទ និងសេចក្តីថ្លៃថ្នូរនៃគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំចាំបាច់ផងដែរ គឺធានាថា យន្តការបណ្តឹងតវ៉ាត្រូវបង្កើតឡើង សម្រាប់អាជីវកម្មស្អាតស្អំ និងសាធារណៈលើកពីកង្វល់ទាក់ទងនឹងនិតីវិធីប្រតិបត្តិរបស់ក្រុមហ៊ុនគាំទ្រអាជីវកម្មស្អាតស្អំ ។ បណ្តឹងតវ៉ានឹងត្រូវដោះស្រាយដោយគណៈកម្មាការអចិន្ត្រៃយ៍អាជីវកម្មស្អាតស្អំ ។

សង្ឃឹមថា ចំនួនក្រុមហ៊ុនអាជីវកម្មមានការចាប់អារម្មណ៍ និងចូលរួមគាំទ្រកើនឡើងនៅពេលគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំប្រកាសជាសាធារណៈ ។ ក្រុមហ៊ុនចំនួន ៤០ បានឯកភាពថានេះជាអាជីវកម្មល្អមួយ ហើយចាំបាច់ណាស់ ដែលត្រូវប្រតិបត្តិឲ្យមានស្តង់ដារខ្ពស់បំផុតមួយ ក៏ដូចនឹងជម្រុញឲ្យមានការប្រកួតប្រជែងយុត្តិធម៌ ។ ដោយគាំទ្រគំនិតផ្តួចផ្តើមអាជីវកម្មស្អាតស្អំ ក្រុមហ៊ុនទាំងនេះបានបង្ហាញពីភាពដឹកនាំអាជីវកម្មរបស់ពួកគេហើយការរួបរួមគ្នា ធ្វើឲ្យអាជីវកម្មទាំងនោះនឹងបង្កើនប្រាក់ចំណេញ ក៏ដូចជាធ្វើឲ្យសេដ្ឋកិច្ចកម្ពុជារីកចំរើនទាំងមូលផងដែរ ។ នាពេលខាងមុខ នឹងមានអាជីវកម្មច្រើនឡើងៗចូលរួមគាំទ្រ និង ឯកភាពឈរលើគោលជំហារមួយដ៏រឹងមាំដើម្បីលើកស្ទួយអាជីវកម្មស្អាតស្អំ ។

សូមស្វែង យល់ព័ត៌មានបន្ថែម តាមរយៈវេបសាយ www.cleanbusiness.com.kh ឬសូមទំនាក់ទំនងមក ប្រធានគណៈកម្មាការអចិន្ត្រៃយ៍ រឺ ផេកកម្ពុជា ៖

- លោក Talmage Payne នាយកប្រតិបត្តិ Hagar Talmage.Payne@hagarinternational.org
- លោក រស់ សុវណ្ណ sovannr@pactcambodia.org ទូរស័ព្ទលេខ 012 881 491
- លោក ស្ទេវិន រូស stevenr@pactcambodia.org ទូរស័ព្ទលេខ 092 320 130